ACCESS
Sustainable quality services for all

Australian Aid

# ការអនុវត្តល្អៗ និងមេរៀនដកបទពិសោធន៍ដើម្បីជំរុញការចូលរួម របស់អង្គការតំណាងជនមានពិការភាពប្រកបដោយអត្ថន័យ ក្នុងដំណើរការវាយតម្លៃពិការភាព

## ១. អភិក្រមវាយតម្លៃលើពិការភាព

**ក្របខណ្ឌគាំពារសង្គមជាក់លាក់សម្រាប់ជនមានពិការភាព** តម្រូវឱ្យមានយន្តការដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃអ្នកដែលមានសិទ្ធិទទួលបានការគាំទ្រផ្អែកលើពិការភាពរបស់ពួកគេ។ មានការជជែកដេញដោលយ៉ាងខ្លាំងផងដែរលើប្រធានបទដ៏រសើបនេះ។ ការយល់ឃើញជាទូទៅអំពីពិការភាព នៅក្នុងប្រទេសកម្ពុជាត្រូវបានឆ្លុះបញ្ចាំងនិងប្រើប្រាស់ជាមូលដ្ឋានក្នុងការវាយតម្លៃនេះ។

**អភិក្រមផ្អែកលើសិទ្ធិជាមូលដ្ឋាន គឺជាការវាយតម្លៃពិការភាពដ៏សមប្រកបបំផុតដូចមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ របស់អង្គការសហប្រជាជាតិ** (CRPD)។ CRPD កំណត់ពិការភាពដោយប្រើប្រាស់គំរូសង្គមដែលទទួលយកពិការភាពផ្នែករាងកាយ ផ្លូវចិត្ត បញ្ញា ឬសតិអារម្មណ៍ អន្តរកម្មនៃពិការភាពទាំងនេះជាមួយនឹងរបាំងឧបសគ្គសង្គម ដែលកំណត់អំពីកម្រិតធ្ងន់ធ្ងរនៃពិការភាពនីមួយៗ។

**អភិក្រមវាយតម្លៃពិការភាពតផ្អែកលើសិទ្ធិជាមូលដ្ឋាន ដែលត្រឹមត្រូវបំផុតមួយនោះ ត្រូវមានធាតុផ្សំដូចតទៅ៖**

- **ផ្តោតលើកត្តាផ្សេងៗដែលនាំឱ្យមានរបាំងឧបសគ្គ ដល់ជនមានពិការភាព** ជាជាងបញ្ហាសុខភាព ឬ វិកលសម្បទារបស់ពួកគេ។
- **អាចរកបាន និងប្រើប្រាស់បានសម្រាប់ជនមានពិការភាពគ្រប់រូប** នៅគ្រប់ទីកន្លែងទូទាំងប្រទេស
- **មិនបង្កឱ្យមានការដាក់បន្ទុកបន្ថែមដល់ការរើសអើង** ឬជាការរឹតត្បិតសិទ្ធិរបស់ជនមានពិការភាព
- **គោរពសេចក្តីថ្លៃថ្នូរ** ស្វ័យភាព និងឯកជនភាពរបស់មនុស្ស
- **មានលក្ខណៈសាមញ្ញ តម្លាភាព គណនេយ្យភាព** និងមានយន្តការដោះស្រាយបណ្តឹងច្បាស់លាស់

ខែធ្នូ ឆ្នាំ២០២២

**ការចូលរួមរបស់ជនមានពិការភាព និងអង្គការតំណាងជនមានពិការភាព** (OPDs) ក្នុងការវាយតម្លៃពិការភាព **គឺជាធាតុផ្សំ ដ៏សំខាន់មួយ** របស់អភិក្រមផ្អែកលើសិទ្ធិ។ នេះជាការចាំបាច់ណាស់ដែលត្រូវបង្កលទ្ធភាពឱ្យមាន ការឆ្លុះបញ្ចាំងនិងដាក់បញ្ចូលទស្សនទាននិងបទពិសោធន៍របស់ជនមានពិការភាពទៅក្នុងកិច្ចដំណើរការយន្តការ ការរៀបចំបង្កើត ការអនុវត្ត ការត្រួតពិនិត្យ និងគណនេយ្យភាពនៃការវាយតម្លៃ។
**វិធីសាស្រ្តកំណត់អត្តសញ្ញាណ និងវាយតម្លៃពិការភាពចំនួនបី** ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅតាមបណ្តាប្រទេសក្នុងលោក។ សូមមើលលក្ខណៈសំខាន់ៗរបស់វិធីសាស្រ្តនីមួយៗ ក្នុងតារាងសង្ខេបខាងក្រោម៖

| អភិក្រម | វិកលសម្បទា | អសមត្ថភាពការងារ | ពិការភាព |
|---|---|---|---|
| វិសាលភាព | **ជាការវាយតម្លៃផ្អែកវេជ្ជសាស្រ្ត** ដើម្បីកំណត់អំពីស្ថាន ភាពសុខភាព កម្រិតនិងភាព ធ្ងន់ធ្ងរនៃភាពចុះខ្សោយជា ភាគរយនៃទិដ្ឋភាពរួមដែលថមថយ។ | **ជាការវាយតម្លៃសមត្ថភាពបំពេញមុខងារ** - ដូចជា ការលើកដាក់ ឈរ កាន់ ស្តាប់ គំហើញ ការចងចាំ ការផ្ទង់ស្មារតី និងកម្រិតនៃវិសាលភាពទាំងនោះ។ ជារឿយៗ ភ្ជាប់ជាមួយនឹងការវាយតម្លៃផ្អែកវេជ្ជ សាស្រ្ត។ | **ជាការវាយតម្លៃវិសាលភាពផលប៉ះពាល់ផ្អែកបរិស្ថាន** លើសមត្ថភាពរបស់បុគ្គលម្នាក់ក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ដោយ មិនគិតអំពីភាពថមថយខាងសមត្ថភាពរបស់ពួកគេ។ អាចត្រូវបានភ្ជាប់ ជាមួយការវាយតម្លៃផ្អែកវេជ្ជសាស្រ្ត និង/ឬសមត្ថភាព បំពេញមុខងារ។ |
| ការផ្តោតចិត្តទុកដាក់ | **ផ្តោតលើបុគ្គល ជាជាងកាយ សម្បទា និងបរិយាកាសសង្គម**ដែលជនមានពិការកំពុងរស់នៅ។ | **ផ្តោតលើបុគ្គល ជាជាងកាយសម្បទា និងបរិយាកាស**សង្គមដែលជនមានពិការកំពុងរស់នៅ។ | **ផ្តោតលើកាយសម្បទានិងបរិយាកាសរាងកាយ**ដែលជនមានពិការកំពុងរស់នៅ។ |
| អនុលោមតាម CRPD | មិនអនុលោមតាមអភិក្រមផ្អែកលើសិទ្ធិដូចមានចែងក្នុង CRPD ទេ។ | **មិនអនុលោម**តាម អភិក្រមផ្អែកលើសិទ្ធិដូចមានចែងក្នុង CRPD ទាំងស្រុង។ | មិនអនុលោមតាមអភិក្រមផ្អែកលើសិទ្ធិដូចមានចែងក្នុង CRPD ទេ។ |

**វិធីសាស្រ្តវាយតម្លៃពិការភាព** ខាងលើរួមមាន ការវាយតម្លៃអំពីផលប៉ះពាល់ផ្អែកបរិស្ថាននិងសង្គម និងកត្តាកាយសម្បទាលើសមត្ថភាពបំពេញការងារប្រចាំថ្ងៃ និងអាចបញ្ចូលការវាយតម្លៃផ្អែកវេជ្ជសាស្រ្តអំពីការថមថយ និង/ឬសមត្ថភាពបំពេញមុខងាររបស់បុគ្គលណាម្នាក់។ វិធីសាស្រ្តនេះគឺស្របតាមគំរូសង្គមស្តីពីពិការភាព និងអភិក្រមផ្អែកលើសិទ្ធិ ដូចមានចែងនៅក្នុង CRPD ។
**ប្រទេសជាច្រើនចង់អនុវត្តវិធីសាស្រ្តវាយតម្លៃពិការភាពនេះ តែពុំអាចធ្វើបានដោយសារកត្តាឧបសគ្គផ្នែក ធនធានមនុស្សនិងហិរញ្ញវត្ថុ ក៏ដូចជាពេលវេលា**។ អ្នកឯកទេសដូចជាបុគ្គលិកសង្គមកិច្ច និងអ្នកព្យាបាលដោយចលនា ឬគ្រោះថ្នាក់ការងារដែលត្រូវការដើម្បីបំពេញការវាយតម្លៃផ្អែកសង្គម និងមុខងារមានចំនួនតិចតួច ហើយទោះបីជាមាន ជារឿយៗពួកគេជាប់រវល់បំពេញភារកិច្ចឬកិច្ចការផ្សេងទៀតដែលមានស្រាប់ ហើយពុំអាច ចូលរួមក្នុងដំណើរការវាយតម្លៃបែបនេះបាន។ កង្វះខាតមន្រ្តីសុខាភិបាលដែលមានជំនាញ និងសមត្ថភាព សមស្របគឺជាបញ្ហា

---

[1]Alexandre Cote, UNPRDP-ILO-UNICEF Inclusive Social Protection Initiative, ការពិចារណាលើប្រសិទ្ធភាពចំណាយសម្រាប់ការវាយតម្លៃនិង យន្តការកំណត់អត្តសញ្ញាណពិការភាពស្របតាមស្តង់ដារ CRPD សម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាប (LMICs) ខែវិច្ឆិកា ឆ្នាំ២០២០

ប្រយោមមួយទៀតក្នុងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ។ បន្ថែមលើនេះ បើទោះបីគាត់ជាគ្រូពេទ្យ ក៏ដោយក៏មិនប្រាកដថាគាត់មានជំនាញវាយតម្លៃផ្នែកវេជ្ជសាស្ត្រទាក់ទងនឹង ពិការភាពបានត្រឹមត្រូវនោះទេ។

**សូមមើល ឧទាហរណ៍ជាក់ស្តែងស្តីពីការវាយតម្លៃពិការភាព ដូចមានរៀបរាប់នៅក្នុងប្រអប់ទាំងពីរខាងក្រោម៖**

**ប្រអប់ទី ១៖ យន្តការវាយតម្លៃពិការភាពរបស់ ប្រទេសប្រេស៊ីល**

**ប្រទេសប្រេស៊ីលបានអនុម័តជាផ្លូវការចំណាត់ថ្នាក់អន្តរជាតិលើការបំពេញមុខងារ ពិការភាព និង សុខភាព** (ICF) **ជាវិធីសាស្ត្រប៉ាន់ប្រមាណផ្នែក សុខភាពនិងពិការភាពនាឆ្នាំ ២០០៣។** ICF ត្រូវបាន ដាក់បញ្ចូលទៅក្នុងឧបករណ៍វាយតម្លៃគ្រប់ ជ្រុងជ្រោយ ស្តីពីពិការភាព ហើយត្រូវបានប្រើប្រាស់ចាប់តាំងពីឆ្នាំ ២០០៧។ បេក្ខជនត្រូវបានផ្តល់ពិន្ទុផ្នែកលើការចុះខ្សោយ/ជំងឺ ការបំពេញមុខងារ អន្តរកម្មជាមួយបរិស្ថាន ដោយប្រើប្រាស់កម្រងសំណួរដ៏ទូលំទូលាយមួយ។

**នេះគឺជាការអនុវត្តល្អប្រសើរមួយ។ ការរៀបចំបង្កើត ការវាយតម្លៃគឺផ្អែកលើគោលការណ៍របស់** CRPD **។ ទោះជាបែបនេះក្តី ដំណើរការវាយតម្លៃនេះទាមទារ ធនធានច្រើន និងពេលវេលាផងដែរ។** ទាំងមន្ត្រីសុខា ភិបាល និងបុគ្គលិកសង្គមកិច្ចបានចូលរួមក្នុងដំណើរ ការនេះ។ ទិដ្ឋភាពពិការភាពនិងបរិស្ថានរបស់បេក្ខជន ត្រូវបានយកមកពិចារណា។

**ប្រអប់ទី ២៖ ប្រទេសហ្វីជី ការវាយតម្លៃសិទ្ធិទទួលបានគម្រោងប្រាក់ឧបត្ថម្ភ** ( DAS )

**នៅក្នុងការរៀបចំផ្តល់ប្រាក់ឧបត្ថម្ភផ្នែកពិការភាព ប្រទេសហ្វីជីបានសាកល្បង យន្តការថ្មីមួយដើម្បីកំណត់និងវាយតម្លៃលើក្រុមមនុស្សដែលមានសិទ្ធិទទួលបានការឧបត្ថម្ភ** ដោយគិតគូរគ្រប់ជ្រុងជ្រោយអំពីបន្ទុកចំណាយនានាដែលអាចកើតមានឡើងចំពោះជនមានពិការភាព។ គោលការណ៍សិទ្ធិមនុស្ស ត្រូវបានប្រើប្រាស់ជា មគ្គុទេសន៍ចង្អុលបង្ហាញក្នុងការរៀបចំបង្កើត និងអនុវត្តសាកល្បងលើដំណើរការ និងឧបករណ៍ពាក់ព័ន្ធ។ OPDs ចាំបាច់ត្រូវចូលរួមក្នុងគ្រប់ដំណាក់កាល។ ជំហានដំបូងគឺការកំណត់ ជនមានពិការភាពក្នុងសហគមន៍ដែលជាការទទួល ខុសត្រូវរបស់មន្ត្រីសង្គមកិច្ចក្នុងមូលដ្ឋាន និង OPDs។ **ការវាយតម្លៃ**អាចត្រូវបានធ្វើឡើងដោយផ្ទាល់នៅផ្ទះរបស់ជនមានពិការភាព ឬនៅការិយាល័យសង្គមកិច្ចស្រុក / មូលដ្ឋាន ដោយពិនិត្យមើលអំពីតម្រូវក្នុងការបំពេញមុខងារ ជំនួយចាំបាច់ តម្រូវការផ្នែកវេជ្ជសាស្ត្រ និងមុខចំណាយពាក់ព័ន្ធបណ្តាលមកពីពិការភាព។ការវាយតម្លៃនេះកំណត់អំពីសិទ្ធិនិងកម្រិតប្រាក់ឧបត្ថម្ភដែលជនមានពិការភាពត្រូវទទួលបាន។ ជនមានពិការភាពដែលត្រូវបានរកឃើញថាមិនមានសិទ្ធិទទួលបាន DAS នោះមានសិទ្ធិប្តឹងឧទ្ធរណ៍។ ក្នុងករណីនេះ យើងនៅមានជម្រើសផ្សេងទៀត ដោយត្រូវវាយតម្លៃជុំទី២ ដោយមានការចូលរួមពីគ្រូពេទ្យឯកទេសខាងវេជ្ជសាស្ត្រ។ រដ្ឋត្រូវទទួលរ៉ាប់រងលើចំណាយទាំងអស់ក្នុងករណីនេះ ដូចជាថ្លៃធ្វើដំណើរជាដើម។

លទ្ធផលនៃការវាយតម្លៃគម្រោងសាកល្បងជំហានដំបូង (ឆ្នាំ២០១៨-២០២០) ដែលបានគ្របដណ្តប់លើប្រជាជនសរុបចំនួន ០,៩២% គឺជាភាពជោគជ័យមួយ។ ចំនួនអ្នកទទួល DASកើនឡើងដល់ទៅ៣ដងចាប់ពី ២.១៣៣នាក់ (ក្នុងឆ្នាំ២០១៨) ដល់ ៧.០០៣នាក់ (ឆ្នាំ២០២០)។

**ដោយសារធនធានមានកម្រិត ប្រទេសមួយចំនួនបានកែសម្រួលដំណើរការវាយតម្លៃឱ្យសមស្របទៅបរិបទជាក់ស្តែងរបស់ប្រទេសខ្លួននារយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។** សូមមើលឧទាហរណ៍ខាងក្រោម សម្រាប់ ការកែតម្រូវក្នុងការអនុវត្តដូចតទៅ៖

- **រៀបចំបង្កើតការវាយតម្លៃពិការភាពមួយដែលមានលក្ខណៈសាមញ្ញ ដែលអ្នកមានជំនាញតិចតួចអាចប្រើប្រាស់បាន** ក្នុងការកំណត់អត្តសញ្ញាណជនមានពិការភាគច្រើន ហើយយើងមិនភ្លេចទេថាមានករណីពិការភាពមួយចំនួនតូចដែលយើងពិបាកមើលឃើញដែលករណីនេះទាមទារឱ្យមានការវាយតម្លៃពីអ្នកជំនាញឯកទេស។
- **ដំណើរការវាយតម្លៃពីរជំហាន** អាជ្ញាធរមូលដ្ឋានវាយតម្លៃដំបូង បន្ថែមដោយការវាយតម្លៃផ្នែក វេជ្ជសាស្ត្រនៅពេលមានការសង្ស័យ ឬពិបាកសន្និដ្ឋានលើពិការភាពដែលតម្រូវឱ្យមានវិញ្ញាបនប័ត្រ វេជ្ជសាស្ត្រ
- **ការវាយតម្លៃចល័តតាមមូលដ្ឋានគ្រូពេទ្យ** និងបុគ្គលិកសង្គមកិច្ច ចុះទៅវាយតម្លៃនៅសហគមន៍ដាច់ស្រយាល

## ២. ការវាយតម្លៃពិការភាពនៅកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងសហភាពអឺរ៉ុបបានបង្កើតយន្តការ វាយតម្លៃពិការភាព ដែលមានឈ្មោះថាជាយន្តការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន** ( SRDIM )។ យន្តការនេះមានគោលបំណង ផ្តល់ជូនជនមានពិការភាពនូវប័ណ្ណពិការភាព ដែលផ្តល់លទ្ធភាពឱ្យពួកគាត់អាចប្រើប្រាស់សេវាសាធារណៈបានយ៉ាងទូលំទូលាយ ទន្ទឹមនឹងការបង្កើតប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព (DMIS) ។

វិធីសាស្រ្តថ្មីនេះគឺជាជំហានដ៏រីជ្ជមានឆ្ពោះទៅអនុវត្តអភិក្រមផ្អែកលើសិទ្ធក្នុងការវាយតម្លៃពិការភាព ដោយប្រើប្រាស់ វិធីសាស្រ្តរួមបញ្ចូលគ្នារវាង **តម្រូវនៃវេជ្ជសាស្រ្ត** និងសមត្ថភាពបំពេញមុខងារដែលមានកម្រិត និង**តម្រូវទិដ្ឋភាពសង្គមស្តីពីពិការភាព**ជារួម។

ឧបករណ៍វាយតម្លៃត្រូវបានរចនាឡើង ដោយគិតគូរ ទាំងពេលវេលា ចំនួនអ្នកឯកទេស មន្រ្តីស្តារ និងអ្នកព្យាបាលដោយចលនាដែលមានកម្រិតនៅកម្ពុជា។ ឧបករណ៍នេះ ផ្តោតលើការបណ្តុះបណ្តាលដល់ជន បង្គោលក្នុងមូលដ្ឋានដែលមិនមែនជាអ្នកជំនាញឯកទេសរស់នៅក្នុងឬនៅជិតសហគមន៍ ប្រើប្រាស់ក្នុង មូលដ្ឋានដោយផ្ទាល់តែម្តង។ ការវាយតម្លៃនេះក៏អាចធ្វើឡើងនៅផ្ទះអ្នកដាក់ពាក្យ ស្នើសុំដោយផ្ទាល់ក៏បាន។

**គោលបំណង គឺថាអ្នកកាន់ប័ណ្ណសម្គាល់ពិការភាព** មានសិទ្ធប្រើប្រាស់សេវាសាធារណៈបានទូលំទូលាយ រួមទាំងអត្ថប្រយោជន៍ផ្នែកពិការភាព ឱកាសការងារ តាមកូតា កម្មវិធីអប់រំនិងបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈដោយឥតគិតថ្លៃ ការអប់រំ ការពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាល និងសេវាស្តារនីតិសម្បទា។

**ប្រអប់ទី ៣: បទពណ៌នាអំពី យន្តការកំណត់អត្តសញ្ញាណពិការភាពផ្អែកលើសង្គម និងសិទ្ធិ** ( SRDIM )

**ការវាយតម្លៃ ពិនិត្យពិចារណាលើទិដ្ឋភាពដូចតទៅ៖**

- **ពិការភាព ៥ ប្រភេទ** - រាងកាយ វិញ្ញាណ បញ្ញា ស្មារតី និងផ្សេងៗ
- **កម្រិតទាំងបីតាមប្រភេទនីមួយៗ** - ធ្ងន់ធ្ងរបំផុត មធ្យម និងស្រាល
- **សូចនាករសង្គមរួមមាន៖**
  - បុព្វកំណើត
  - ស្ថានភាពក្រីក្រ (ID Poor)
  - លក្ខខណ្ឌ និងបរិយាកាសរស់នៅ
  - កម្រិតជំនួយ និងកិច្ចគាំទ្រដែលត្រូវការ
  - តម្រូវការឧបករណ៍ជំនួយ និងឱសថ
  - សម្រាប់មនុស្សពេញវ័យ ត្រូវប្រមូលទិន្នន័យស្តីពីស្ថានភាពការងារ។
  - សកម្មភាពសង្គម
  - ជំនួយការផ្ទាល់ខ្លួន

ចំណុចសំខាន់ គឺយើងប្រើប្រាស់លេខសម្គាល់តែមួយដើម្បីភ្ជាប់ **ទំនាក់ទំនង**រវាងកម្មវិធីជំនួយសង្គម ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ (IDPoor) និងទិន្នន័យមូលដ្ឋានវាយតម្លៃពិការភាព។ នៅក្នុងបរិបទនេះសម្រាប់កម្មវិធី IDPoor គឺពុំចាំបាច់ប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងពិការភាពទៀតទេ។ ផ្ទុយទៅវិញ ព័ត៌មានរបស់ជនមានពិការនៅលើមូលដ្ឋានទិន្នន័យ IDPoor ត្រូវបានប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃលើសិទ្ធិទទួលបានប័ណ្ណក្រីក្រ IDPoor ។ **ឧបករណ៍វាយតម្លៃនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅទូទាំង២៥** ខេត្តក្រុងក្នុងប្រទេសកម្ពុជា។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** (MoSVY) **បានដាក់ចេញនូវកម្មវិធីបណ្តុះបណ្តាល ថ្នាក់ជាតិ** ផ្តោតលើថ្នាក់ឃុំ-សង្កាត់ ដល់អ្នកពាក់ព័ន្ធចំនួន ៥.៦៣៣ នាក់ ដែលក្នុងនោះ ៤៧.១% ជាស្ត្រី។ **មន្ត្រីឃុំសង្កាត់ដែលទទួលបានបណ្តុះបណ្តាល** (**ទាំងពីរភេទ**) **បានសម្ភាសន៍ដើម្បីអត្តសញ្ញាណពិការភាព** ហើយមន្ត្រីជំនាញរបស់នាយកដ្ឋានសុខុមាលភាពជនពិការ (DWPD) ពិនិត្យផ្ទៀងផ្ទាត់និងផ្តល់សុពលភាព លើលទ្ធផលសម្ភាស៍ និងអនុម័តសិទ្ធិទទួលបានប័ណ្ណសម្គាល់ពិការភាព (ប័ណ្ណជនមានពិការភាព)។ **កម្មវិធី វាយតម្លៃនេះគឺមាននៅតាម** ឃុំនីមួយៗ ហើយ **យន្តការដោះស្រាយបណ្តឹងតវ៉ា** ក៏ត្រូវបានបង្កើតឡើងនៅលំហូរ ប្រតិបត្តិការផងដែរ។

## ៣. ការអនុវត្តល្អ និងអត្ថប្រយោជន៍ដែលទទួលបានតាមរយៈការចូលរួមរបស់ អង្គការតំណាងជនមានពិការភាព (OPDs)

**កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាសម្រាប់ការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌** (ACCESS) គឺជាគំនិតផ្តួចផ្តើមរយៈពេលប្រាំឆ្នាំ (២០១៨-២០២៣) គាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី ផ្តល់តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម (អូស្ត្រាលី)។ ACCESS បានផ្តល់ការគាំទ្រជាច្រើនដើម្បីស្វែងយល់និងលើកកម្ពស់ការយល់ដឹងអំពីតម្រូវការរបស់ជនមានពិការភាព និងឧបសគ្គដែលពួកគេតែងតែជួបប្រទះក្នុងការកំណត់អត្តសញ្ញាណ និងការវាយតម្លៃដ៏ត្រឹមត្រូវមួយដើម្បី ឈានទៅទទួលបាន ការគាំទ្រពីកម្មវិធីគាំពារសង្គមដែលមានកម្ពុជា។ កិច្ចគាំទ្រដែលកម្មវិធី ACCESS ផ្តល់ឱ្យរួមមាន៖

### លើកកម្ពស់ការយល់ដឹងរបស់សមាជិក OPDs អំពីបរិយាបន្នពិការភាពនៅក្នុងជំនួយសង្គម និងសម្របសម្រួលឱកាសឱ្យមានការចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា

- **កិច្ចសន្ទនារវាង** OPDs **និងអ្នកតាក់តែងគោលនយោបាយកម្មវិធីគាំពារសង្គមរៀបចំឡើងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន**ផ្តោតជាពិសេសលើការកំណត់អត្តសញ្ញាណនិងការវាយតម្លៃ ជួយឱ្យ OPDs ទទួលបាន ព័ត៌មានត្រឹមត្រូវអំពីកិច្ចដំណើរការនេះ។

### គាំទ្រដល់ភាគីពាក់ព័ន្ធសំខាន់ៗឱ្យត្រៀមលក្ខណៈរួចរាល់ចូលរួមក្នុងកិច្ចពិភាក្សាស្តីពីបរិយាបន្នពិការភាពក្នុងកិច្ចគាំពារសង្គម

- **បណ្តុះបណ្តាល** OPDs ស្តីពីកម្មវិធីគាំពារសង្គម និងសិទ្ធិផ្អែកលើការអនុវត្តល្អនៅកម្ពុជានិងអន្តរជាតិ។ ការបណ្តុះ បណ្តាលសំដៅផ្តល់ព័ត៌មាននិងបង្កើនចំណេះដឹងជម្រុញឱ្យមានការតស៊ូមតិនិងការសន្ទនារវាង OPDs និង RGC ។
- **ក្នុងការគិតគូរពីផលប្រយោជន៍របស់ជនមានពិការភាព កម្មវិធី** ACCESS **បានបង្ហាញអំពីគោលគំនិតស្តីពីបរិយាបន្នពិការភាពក្នុងកិច្ចគាំពារសង្គមជូនដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម** (NSPC-GS) ក៏ដូចជាស្វះស្វែងរកលទ្ធភាពផ្សេងទៀតដែលកម្មវិធី ACCESS អាចរួមចំណែកបានច្រើនបន្ថែមទៀតក្នុងវិស័យនេះ។ មន្ត្រីរាជការបួនរូប និងបុគ្គលិកអង្គការ OPD - អង្គការជនពិការកម្ពុជា (CDPO) ២រូបបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស៊ីជម្រៅស្តីពីទិដ្ឋភាពផ្សេងៗនៃបរិយាបន្នពិការភាពក្នុងកិច្ចគាំពារសង្គម។

### ការអប់រំតាមរយៈកិច្ចសន្ទនា

- **កម្មវិធី** ACCESS **បានសម្របសម្រួលនិងផ្តល់កិច្ចគាំទ្រជាបន្តបន្ទាប់លើការរៀបចំកិច្ចសន្ទនាថ្នាក់ជាតិរវាង** OPDs **និងភាគីពាក់ព័ន្ធរបស់** RGC **ស្វែងរកច្រកចេញលើការដាក់បញ្ចូលពិការភាពទៅក្នុងប្រព័ន្ធគាំពារ សង្គមរបស់កម្ពុជាចំនួន៤ដង**។ កិច្ចសន្ទនាទាំងនេះផ្តល់លទ្ធភាពឱ្យថ្នាក់ដឹកនាំ OPD ទទួលបានព័ត៌មាន ថ្មីៗអំពីមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ស្តីពីដំណើរការកំណត់គោលដៅ និងអត្ថប្រយោជន៍ពីគម្រោង ជំនួយសង្គមដែលមាន។

ក្រោយកិច្ចសន្ទនាទាំងនេះ OPDs បានផ្សព្វផ្សាយព័ត៌មាននេះបន្តដល់ សមាជិកខ្លួននៅតាមសហគមន៍។ កិច្ចការនេះបានជួយដល់ OPDs ក្នុងមូលដ្ឋាននិងសមាជិកខ្លួនយល់ដឹង បានច្បាស់អំពីសិទ្ធិរបស់ខ្លួនក្នុងការចូលរួមនិងតស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធានាថាខ្លួនពិតជា អាចទទួលបានអត្ថប្រយោជន៍ តាមរយៈការកំណត់អត្តសញ្ញាណសមស្រប រួមទាំងដំណើរការវាយតម្លៃ។

- **មន្ត្រីរាជការពី** MoSVY, NSPC-GS **និងក្រសួងផែនការក៏ទទួលបានអត្ថប្រយោជន៍ដូចគ្នាផងដែរ តាមរយៈការចែករំលែកនិងលើកឡើងត្រង់ៗពី** OPDs **ស្តីពីអត្ថប្រយោជន៍ផ្នែកគាំពារសង្គម**ដល់ជនមាន ពិការភាព។ ពួកគេ បានលើកឡើងថាកិច្ចសន្ទនាទាំងនេះពិតជាមានប្រយោជន៍ខ្លាំង។ ទោះបីជាមន្ត្រីរដ្ឋ ធ្លាប់បានស្តាប់លឺរួចមកហើយអំពីក្តីកង្វល់ទាំងនេះ ប៉ុន្តែការលើកឡើងដោយ OPDs ផ្ទាល់ ពិតជាមានតម្លៃ និងឥទ្ធិពលធំធេងជាប្រាកដ។ កិច្ចសន្ទនានេះមិនត្រឹមតែផ្តល់ឱកាសឱ្យមន្ត្រីរាជរដ្ឋាភិបាលបានស្តាប់លឺអំពី បញ្ហាប្រឈមដែលជនមានពិការភាពជួបប្រទះ ប៉ុន្តែជាការបង្ហាញឆន្ទៈដ៏មុតមាំរបស់ពួកគេ តាមរយៈ ការចូលរួមដោយផ្ទាល់ព OPDs ដើម្បីបង្កើតឱ្យមានលទ្ធផលជាវិជ្ជមានស្តីពីបរិយាបន្នពិការភាពក្នុងកិច្ច គាំពារសង្គម។[2]

## កិច្ចសហប្រតិបត្តិការជាក់ស្តែង

- **បន្ទាប់ពីជំនួបដំបូង កិច្ចសហការរវាង** OPDs **និង** RGC **លើបរិយាបន្នពិការភាពក្នុកិច្ចគាំពារសង្គមមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់**។ តំណាងពី OPD ប្រមាណ៥០រូបបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន (SRDIM) ដែលរៀបចំដោយនាយកដ្ឋានសុខុមាលភាព ជនពិការរបស់ MoSVY ដើម្បីលើកកម្ពស់ការយល់ដឹងអំពីឧបករណ៍ និងកិច្ចដំណើរការ។
- **នៅថ្នាក់ក្រោមជាតិ កម្មវិធី** ACCESS **បានបង្កលក្ខណៈឱ្យអង្គការជនពិការកម្ពុជា** ( CDPO )**សម្របសម្រួលកិច្ចសហការរវាង** OPDs **និង** RGC ។ អង្គការតំណាង OPD និងសហព័ន្ធស្ត្រីមានពិការភាពចំនួនប្រាំពីរនៅក្នុងខេត្តកំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ សៀមរាប បាត់ដំបង ក្រចេះ និងស្វាយរៀង បានជួយ **សម្របសម្រួលការចុះឈ្មោះរបស់ជនមានពិការភាព**។ អង្គការតំណាង OPDsសហការជាមួយ អាជ្ញាធរឃុំក្នុងការជូនដំណឹងដល់សមាជិកខ្លួនអំពីដំណើរការកំណត់អត្តសញ្ញាណជនមានពិការនិង ពេលវេលា ដែល នឹងត្រូវប្រព្រឹត្តឡើងនាពេលខាងមុខ រួមទាំងជូនដំណឹងដល់អាជ្ញាធរក្នុងករណីដែល ខកខានមិនបាន ចុះឈ្មោះបុគ្គលណាម្នាក់នោះ។ ក្នុងដំណើរចុះពិនិត្យជាក់ស្តែងកាលពីពេលថ្មីៗនេះ នៅខេត្តត្បូងឃ្មុំ និងកំពង់ចាម អាជ្ញាធរឃុំបានសម្តែងការកោតសរសើរដល់អង្គការតំណាង OPD សម្រាប់ការចូលរួម និងគាំទ្រក្នុងការកំណត់អត្តសញ្ញាណជនមានពិការនៅក្នុងសហគមន៍របស់ពួកគេ។

## ការប្រាស្រ័យទាក់ទង

**ដើម្បីគាំទ្រការចែករំលែកព័ត៌មានដែលអាចទុកចិត្តបានដល់កម្រិតសហគមន៍** ACCESS **បានផ្តល់មូលនិធិដល់** CDPO **ដើម្បីបង្កើតកញ្ចប់ទំនាក់ទំនង** លើគម្រោងគាំពារសង្គមដែលមានស្រាប់ ដែល OPDs តាមមូលដ្ឋាន អាចប្រើប្រាស់ក្នុងការជូនដំណឹងដល់សមាជិកខ្លួន។
**ការគាំទ្ររបស់កម្មវិធី** ACCESS **ដល់** OPDs **និង** RGC **ផ្តល់ផលជាវិជ្ជមាននិងជម្រុញទឹកចិត្តខ្ពស់** ជាពិសេសការយល់ដឹងអំពីបរិយាបន្នពិការភាពក្នុងកិច្ចគាំពារសង្គម និងការចូលរួមក្នុងដំណើរការវាយតម្លៃកាន់តែប្រសើរឡើង។

---

[2]ករណីសិក្សារបស់កម្មវិធី ACCESS ការផ្លាស់ប្តូរដ៏សំខាន់ - ដំណើរឆ្ពោះទៅរកប្រព័ន្ធគាំពារសង្គមដែលដាក់បញ្ចូលពិការភាពកាន់តែប្រសើរ

អាសយដ្ឋាន៖ អគារលេខ២៤០ ជាន់ទី៣ អគារ អានីណា ផ្លូវ២៧១
សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ១២ ៨៧៦ ៥៩៩
អីុម៉ែល៖ info@accesscambodia.org
វេបសាយ៖ www.accesscambodia.org

**ការគាំទ្ររបស់កម្មវិធី ACCESS ដល់ OPDs និង RGC ផ្តល់ផលជាវិជ្ជមាននិងជម្រុញទឹកចិត្តខ្ពស់** ជាពិសេសការយល់ដឹងអំពីបរិយាបន្នពិការភាពក្នុងកិច្ចគាំពារសង្គម និងការចូលរួមក្នុងដំណើរការវាយតម្លៃកាន់តែប្រសើរឡើង។

**យន្តការ SRDIM ត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃ និងចុះឈ្មោះជនមានពិការភាពទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព** (DMIS) ដែលផ្តល់លទ្ធភាពឱ្យជនមានពិការភាពអាចទទួលអត្ថប្រយោជន៍បាន។ គិតត្រឹមចុងខែមិថុនាឆ្នាំ២០២២ អាជ្ញាធរថ្នាក់ជាតិបានប្រមូលទិន្នន័យជនមានពិការភាពសរុបបានចំនួន ២៣៤.០៩៤នាក់ (ស្រី ១១៤.២១៥) ក្នុងចំណោមនេះ ជនមានពិការភាពចំនួន ២០០.០០០នាក់ នឹងទទួល បានប័ណ្ណពិការភាពនៅក្នុងឆ្នាំ ២០២២ ដែលពួកគេអាចប្រើប្រាស់ដើម្បីទទួលអត្ថប្រយោជន៍ ពីប្រព័ន្ធគាំពារសង្គម និងសេវាគាំទ្រផ្សេងៗទៀតបានកាន់តែប្រសើរ។ ជនមានពិការភាពដែលមានប័ណ្ណIDPoor ហើយបាន ចុះឈ្មោះក្នុង DMISអាចទទួលបានការឧបត្ថម្ភពីកម្មវិធីផ្ទេរសាច់ប្រាក់ ខណៈពេលដែលអត្ថប្រយោជន៍ ជាក់លាក់ផ្សេងទៀតផ្អែកពិការភាពដែលត្រូវផ្តល់ជូន កំពុងត្រូវបានរៀបចំ។

OPDs **នៅក្នុងខេត្តនិងស្រុកទទួលបានព័ត៌មានច្បាស់លាស់អំពីអត្ថប្រយោជន៍សង្គមដែលសមាជិករបស់ខ្លួន អាចទទួលបាន និងដំណើរការពាក់ព័ន្ធ**។ កិច្ចការនេះបានលើកកម្ពស់ការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ បានកាន់តែខ្លាំង និងមានប្រសិទ្ធភាពជាងមុនដើម្បីជាប្រយោជន៍ដល់សមាជិកខ្លួន។

> **ប្រអប់ទី ៤៖ ការគាំទ្រដល់កំណែទម្រង់បរិយាប័ន្នពិការភាព ក្នុងកិច្ចគាំពារសង្គម តាមរយៈកិច្ចសន្ទនាផ្អែកលើភស្តុតាង**
>
> "កិច្ចពិភាក្សាស្តីពីពិការភាពស្ទើរតែត្រូវបានគេបំភ្លេចចោលទៅហើយ ខ្ញុំសប្បាយចិត្តណាស់ដែលចាប់ផ្តើមជជែកគ្នាអំពីប្រធានបទនេះ។ វាជួយឱ្យយើងបង្វែរពីការពិភាក្សាផ្អែកលើ "អារម្មណ៍" ទៅជាការពិភាក្សា ផ្អែកលើភស្តុតាង។ ការវិភាគនេះផ្តល់ភស្តុតាងនិងភាពរឹងមាំបន្ថែម សម្រាប់កំណែទម្រង់ និងជម្រើសផ្សេងៗផ្អែកតាមទិដ្ឋភាព បច្ចេកទេស»។
> ឯកឧត្តមបណ្ឌិត **ចន ណារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម។

OPDs **និងសមាជិកបាននិងកំពុងរួមចំណែកយ៉ាងសកម្មក្នុងគ្រប់ទិដ្ឋភាពនៃដំណើរការកំណត់អត្តសញ្ញាណ និងការវាយតម្លៃ** ដែលធ្វើឡើងនៅសហគមន៍មូលដ្ឋាន។ OPDs យល់ដឹងកាន់តែច្បាស់ក្នុងការត្រួតពិនិត្យ លើប្រព័ន្ធវាយតម្លៃ និងការចុះឈ្មោះថាបានរៀបចំឡើងត្រឹមត្រូវ និងយុត្តិធម៌ដែរឬទេ។ សមត្ថភាពនិង ការចូលរួមដ៏ល្អប្រសើរនេះពិតជានឹងរួមចំណែកធានាបាននិរន្តរភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធថ្មីដែលកំពុងត្រូវបានបង្កើតឡើងនិងដាក់ឱ្យអនុវត្តនាពេលនេះ។

**ការចូលរួមរបស់មន្ត្រីរាជការជាមួយ** OPDs **នៅក្នុងវេទិកា និងការបណ្តុះបណ្តាលដោយផ្ទាល់ នៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋានបានរួមចំណែក លើកកម្ពស់ចំណេះដឹង និងការស្វែងយល់បន្ថែម** អំពីពិការភាព ក៏ដូចជាពង្រឹងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរបស់ពួកយើង។

## ៤. ជំហានឆ្ពោះទៅទទួលស្គាល់តួនាទីរបស់ OPDs ក្នុងការកំណត់អត្តសញ្ញាណ ជនមានពិការភាព

**ផ្អែកលើបទពិសោធន៍អន្តរជាតិ និងការអនុវត្តនៅកម្ពុជានាពេលថ្មីៗ យើងអាចពិចារណាលើយុទ្ធសាស្ត្រ មួយចំនួនបន្ថែមទៀត ដើម្បីពង្រឹងការចូលរួមរបស់** OPDs **ក្នុងយន្តការកំណត់អត្តសញ្ញាណ និងវាយតម្លៃ ពិការភាព៖**

**យុទ្ធសាស្ត្រទំនាក់ទំនងត្រូវតែមានភាពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាថាជនមានពិការភាព យល់ដឹងអំពីអត្ថិភាពនៃយន្តការវាយតម្លៃ និងអាចប្រើប្រាស់បាន។**

**យុទ្ធសាស្ត្រទំនាក់ទំនងជោគជ័យនិងមានថវិកាគាំទ្រគ្រប់គ្រាន់ ចាំបាច់ត្រូវប្រើប្រាស់គ្រប់ច្រក និងបណ្តាញរួមទាំង** ស្នើសុំការគាំទ្រពី OPDs និងប្រើប្រាស់មធ្យោបាយទំនាក់ទំនងណាដែលសមប្រកបទៅនឹង តម្រូវការ និងសមត្ថភាព

របស់ជនមានពិការភាព ដែលកិច្ចការនេះពិតជានឹងរួមចំណែកជំរុញការផ្សព្វផ្សាយអំពីដំណើរ ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃពិការភាពបានកាន់តែប្រសើរ។ ការប្រើប្រាស់អក្សរស្ទាប ភាសាសញ្ញាឬសេវាបកប្រែផ្សេងៗចាំបាច់ត្រូវដាក់បញ្ចូលសម្រាប់ជនមានពិការភាពដែលមានបញ្ហាផ្នែកអក្ខរកម្ម។ យុទ្ធសាស្ត្រទំនាក់ទំនងច្បាស់លាស់ និងអាចប្រើប្រាស់បានមិនត្រឹមតែអាចធានាសិទ្ធប្រើប្រាស់របស់ជនមាន ពិការភាព តែក៏ជារបាំងត្រួតពិនិត្យមើលអ្នកដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីកាត់បន្ថយសម្ពាធ លើប្រព័ន្ធទាំងមូល។

### ការលើកកម្ពស់ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋានទទួលបន្ទុកកំណត់អត្តសញ្ញាណផ្អែកលើស្ថានភាពពិការភាពនិងពង្រឹងសមត្ថភាពរបស់ OPDs ឱ្យចូលរួមក្នុងដំណើរការនេះ

យុទ្ធសាស្ត្រនេះរួមបញ្ចូល៖

- ការបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងអំពីពិការភាព រួមទាំងការបណ្តុះបណ្តាលជាប់ជាប្រចាំដល់បុគ្គលិកដែលចូលរួមក្នុងដំណើរការវាយតម្លៃ
- ការចូលរួមរបស់ OPDs ក្នុងដំណើរការផ្សព្វផ្សាយ ការកំណត់អត្តសញ្ញាណ និងដំណើរការវាយតម្លៃ
- ការចូលរួមរបស់ OPDs តាមដានលើសេវា និងកែលម្អសេវាផ្អែកតាមបទពិសោធន៍ ជាក់ស្តែង
- ការពង្រឹងធនធាន និងសមត្ថភាព OPDs ដើម្បីលើកកម្ពស់ការចូលរួមប្រកបដោយអត្ថន័យ និងគាំទ្រ ពីរដ្ឋបាលមូលដ្ឋានក្នុងការផ្តល់សេវាកម្ម និងការកែលម្អប្រព័ន្ធទាំងមូល

### ជនមានពិការភាពគ្រប់រូបទទួលបានការវាយតម្លៃដោយស្មើភាព ប្រកបដោយសមធម៌ដោយចំណាយតិចតួច ឬពុំមានចំណាយ

- ទូទាត់សងថ្លៃធ្វើដំណើរ តាមភាពជាក់ស្តែង
- រ៉ាប់រងចំណាយលើការធ្វើតេស្តឬការវាយតម្លៃពិសេសជាក់លាក់ណាមួយ តាមភាពស្មុគស្មាញជាក់ស្តែង
- ធានាថានៅតាមទីតាំងឃុំសង្កាត់ មានបំពាក់បរិក្ខារជាសុករវត្ថុស្របតាមពិការភពផ្សេងៗ ដូចជា បង្កាន់ដៃជម្រាល ការបកប្រែសញ្ញាអក្សរស្ទាបសម្រាប់ជនពិការភ្នែក ទម្រង់ឬរូបផុសសម្រាប់ អ្នកពិការគំហើញ និងការបកប្រែភាសាសញ្ញាតាមការចាំបាច់។

### យន្តការបណ្តឹងឧទ្ធរណ៍ ការត្រួតពិនិត្យនិងការវាយតម្លៃដែលមានការចូលរួមយ៉ាងទូលំទូលាយពីជនមានពិការភាព និងអង្គការតំណាង

**សម្លេងនិងទស្សនៈរបស់ជនមានពិការភាពត្រូវបានទទួលយកក្នុងការអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃក៏ដូចជាកែលម្អប្រព័ន្ធដែលកំពុងដំណើរការ។** កិច្ចការនេះអាចអនុវត្តទៅបានតាមរយៈកិច្ចសន្ទនាជាទៀងទាត់ជាមួយ OPDs នៅគ្រប់កម្រិត និងការស្ទង់មតិ លើការពេញចិត្តរបស់អ្នកដាក់ពាក្យស្នើសុំនិងអ្នកប្រើសេវា។ បន្ថែមលើនេះ យន្តការបណ្តឹងតវ៉ានិងបណ្តឹងសារទុក្ខ ត្រូវមានភាពងាយស្រួល ដែលជនមានពិការភាពគ្រប់ទម្រង់អាចប្រើប្រាស់បាន។ OPDs អាចដើរតួនាទីប្រមូលបញ្ហាប្រឈមក្នុងដំណើរការកំណត់អត្តសញ្ញាណ ដែលសមាជិកខ្លួនជួបប្រទះ។

